# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ហេតុអ្វីបានជាសាលាក្តីកម្ពុជាមានសារសំខាន់ចំពោះសហគមន៍អន្តរជាតិ

បន្ទាប់ពីមួយទសវត្សរ៍នៃកិច្ចចរចាដ៏រំដើបរំជួលដែលជាញឹកញាប់ទទួលបរាជ័យ ប៉ុន្តែវាមានសារសំខាន់សម្រាប់ចងចាំទុក ដែលជំរុញឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបច្ចុប្បន្ន ។ មេធាវីនិងចៅក្រមកំពុងតែស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជាប្រមាណ ១,៧ លាននាក់ ដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ដែលគ្រប់គ្រងអំណាចខែមេសា ឆ្នាំ១៩៧៥ រហូតដល់ខែមករា ឆ្នាំ ១៩៧៩ ។ ៣០ឆ្នាំមកហើយ តាំងពីវាលពិឃាតក្នុងប្រទេសកម្ពុជាបានបង្កើតឡើងដោយរបបប៉ុលពត ដែលមានមនុស្សជាច្រើនស្លាប់បាត់បង់ជីវិត និងប្រើប្រាស់ប្រជាជនខ្មែររាប់លាននាក់ទៀតប្រៀបដូចជាទាសករ ។ ហេតុអ្វីបានជាសហគមន៍អន្តរជាតិគួរតែយកចិត្តទុកដាក់ចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ ជាពិសេសពេលវេលាបានកន្លងហួសអស់ជាច្រើនឆ្នាំ ហើយមានតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនតូចប៉ុណ្ណោះដែលនៅរស់រានមានជីវិត និងក្នុងពេលមួយដែរប្រទេសកម្ពុជាស្ថិតក្នុងសន្តិភាពបែបនេះ? ហេតុអ្វីបានជាសហគមន៏អន្តរជាតិចំណាយលើតុលាការកូនកាត់ដែលប្រកបដោយការប្រថុយប្រថាន និងលទ្ធផលមិនច្បាស់លាស់បែបនេះ? ចម្លើយ គឺស្ថិតនៅលើការខិតខំប្រឹងប្រែងឥតឈប់ឈរដើម្បីបំបាត់ចោលនូវនិទណ្ឌភាពឧក្រិដ្ឋកម្មដ៏ឃោរឃៅ (អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម) ដើម្បីឲ្យយើងដឹងពីអតីតកាល បច្ចុប្បន្នកាល ហើយនឹងមិនមានការប៉ះពាល់ដល់អនាគត ។

មិត្តរួមការងាររបស់ខ្ញុំនៅភ្នំពេញ លោក ឆាំង យុ ជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានសរសេរអត្ថបទអមជាមួយគ្នាដែលពន្យល់អំពីសារសំខាន់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចំពោះប្រជាជនកម្ពុជា ។ នៅក្នុងអត្ថបទនេះខ្ញុំអធិប្បាយដោយសង្ខេបពីហេតុផលដែលអង្គជំនុំជម្រះវិសាមញ្ញគួរតែមានសារសំខាន់ចំពោះសហគមន៍អន្តរជាតិ ។ ដោយមានឧបសគ្គរបស់តុលាការផ្សេងទៀតនៅក្នុងឧក្រិដ្ឋកម្មដ៏ឃោរឃៅផ្សេងទៀតនៅក្នុងពិភពលោករួមទាំងសាលាក្តីឧក្រិដ្ឋកម្មសង្គ្រាមជាច្រើនផ្សេងទៀតទាមទារឲ្យការឧបត្ថម្ភខាងថវិកានិងនយោបាយពីជាតិផ្សេងៗ ។ តើសហគមន៏អន្តរជាតិអាចពេញចិត្តនិងបន្តជំនួយរបស់ខ្លួនដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ?

ខ្ញុំនឹងផ្តល់ចម្លើយខ្លះទៅនឹងសំណួរនេះ ៖

នៅអំឡុងពេលកិច្ចចរចាដែលចាប់ផ្ដើមតាំងពីឆ្នាំ១៩៩៧ ខ្ញុំតែងតែប្រឈមមុខនឹងទស្សនៈអវិជ្ជមានថា ការស្វែងរកយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មឃោរឃៅនៅក្នុងរបបប៉ុលពតគឺជាការព្យាយាមមួយដោយអស់សង្ឃឹម ខ្ញុំរំពឹកដល់មនុស្សដែលមើលឃើញតែរឿងអវិជ្ជមាន (មានមនុស្សបែបនេះច្រើនណាស់) ថា យើងមានការទទួលខុសត្រូវខ្ពស់ចំពោះមនុស្សដែលបានស្លាប់នៅក្នុងប្រទេសកម្ពុជា ដោយនាំយកជនដែដល់ជាន់ខ្ពស់ទៅកាត់ទោស ។ ខ្ញុំមិនអាចមានសតិសម្បជញ្ញៈចរចានឹងការបង្កើតសាលាក្ដីសម្រាប់ជម្លោះនៅបាល់កង់នៅដើមសតវត្សរ៍ទី១៩៩០ អំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដាឆ្នាំ១៩៩៤ អំពីអំណាចឃោរឃៅនៅចុងសតវត្សរ៍ឆ្នាំ១៩៩០ ឬក៏តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ជាអចិន្ត្រៃយ៍ ដោយមិនអើពើនឹងអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាកាលពីចុងសតវត្សរ៍ឆ្នាំ១៩៧០នោះទេ ។ សហគមន៍អន្តរជាតិគួរតែពុំបោះបង់ចោលឧបសគ្គខាងប្រព័ន្ធតុលាការកំពុងកើតមានចេញពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរមកលើប្រជាជនខ្មែរ នៅខណៈពេលដែលពិភពលោកមិនបានយកចិត្តទុកដាក់នៅក្រោយសោកនាដកម្មនៅក្រោយសង្គ្រាមនៅវៀតណាម ។ ដោយឡែកសម្រាប់ជនជាតិអាមេរិក ការទម្លាក់គ្រាប់បែកដោយសម្ងាត់របស់អាមេរិកលើទឹកដីកម្ពុជានៅអំឡុងពេលកាន់អំណាចរបស់លោកប្រធានាធិបតី នី សុន ធ្វើឲ្យប្រទេសនោះគ្មានស្ថិរភាព ធ្វើឲ្យខ្មែរក្រហមបានកំពុងតែបង្កើនអំណាច ។ រឿងនេះធ្វើឲ្យយើងគ្មាន ជម្រើសសីលធម៌ ប៉ុន្តែយើងធ្វើការប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីសម្រេចបាននូវវិធានការដាក់ឲ្យមានការទទួលខុសត្រូវចំពោះការសម្លាប់រង្គាលដែលបានកើតមាន ។ ប្រសិនបើសារដែលគ្មានប្រយោជន៍ បន្ទាប់ពីសង្គ្រាមលោកលើកទីពីរ “មិនកើតឡើងម្ដងទៀត” នោះមេរៀនសំខាន់សម្រាប់ប្រជាជនខ្មែរ ដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្ដែងចំពោះប្រជាជនកម្ពុជានោះគឺ *“មិនអាចបំភ្លេចបាន”* ។ ប្រហែលជាគោលបំណងសំខាន់ជាងគេរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចេញពីទស្សនអន្តរជាតិនោះគឺចង្អុលបង្ហាញ និងជំរុញឲ្យអង្គជំនុំជម្រះបន្តដើរតួនាទីស្របទៅនឹងច្បាប់ដែល ធ្វើរួចនេះដើម្បីធានាថានិទណ្ឌភាពនឹងមិនមានចំពោះមេដឹកនាំខ្មែរក្រហម ឬអ្នកដែលត្រូវទទួលខុសត្រូវ ខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដ៏ឃោរឃៅនៅក្នុងរបបប៉ុលពតនោះទេ ។ ការពិតមួយដែលផ្ដល់សញ្ញាណ ដ៏មានប្រសិទ្ធភាពទៅកាន់ទូទាំងពិភពលោក ដែលសហគមន៍អន្តរ-ជាតិយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការទទួលខុសត្រូវនៃឧក្រិដ្ឋកម្មដ៏សាហាវ ដែលយុត្តិធម៌នៅតែមានរហូត ។ ប្រសិនបើអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជាមានការកាត់ក្ដីដ៏យុត្តិធម៌ស្របតាមដំណើរការច្បាប់ត្រឹមត្រូវរបស់បទដ្ឋានអន្តរជាតិ នោះការកាត់ទោសដោយមានសុភវិនិច្ឆ័យទៅលើភាពគ្មានទោសឬក៏មានទោសនឹងលេចឡើង ជាសញ្ញានៃក្ដីសង្ឃឹមសម្រាប់ជនរងគ្រោះទាំងអស់នៃអំពើបំពានទៅលើមនុស្សជាតិ ។ គេនឹងយល់ថា ប្រសិនបើយុត្តិធម៌អាចកាត់សេចក្ដីបាននៅក្នុងប្រទេសកម្ពុជានៅ

រយៈពេលពាទសវត្សរ៍បន្ទាប់ពីវិនាសកម្មនោះប្រជាជនកម្ពុជានឹងមានសង្ឃឹមថា ខ្លួនក៏អាចបង្កើតឬស្វែងរកតុលាការដែលផ្តល់យុត្តិធម៌ពិតដល់ខ្លួនមិនខាន ។ ប្រសិនបើការកាត់ទោសមិនដំណើរការក្នុងពេលភ្លាមៗ ក្រោយមកក៏នឹងមានការដាក់ទោសដែរ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាតុលាការដែលមានភាពប៉ុនប្រសប់តែមួយគត់ដែលសហគមន៍អន្តរជាតិនឹងផ្តោតទៅលើថាតើតុលាការនេះសម្រេចបានតាមគោលការណ៍និងសុចរិតភាព ឬគ្រាន់តែធ្វើតាមឥទ្ធិពលនិងការរៀបចំខាងនយោបាយ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមែនជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ប៉ុន្តែជាតុលាការពិសេសក្នុងស្រុករបស់កម្ពុជា ដែលមានការសហការពីអង្គការសហប្រជាជាតិ គោរពតាមសន្ធិសញ្ញាដែលយកច្បាប់អន្តរជាតិ និងដំណើរការច្បាប់ត្រឹមត្រូវរបស់បទដ្ឋានអន្តរជាតិ តុលាការពិសេសនៅសេរ៉ាឡេអូនដែលបង្កើតឡើងដោយសន្ធិសញ្ញារវាងរដ្ឋាភិបាលរបស់សេរ៉ាឡេអូន និងអង្គការសហប្រជាជាតិ គឺជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិ រីឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានតាក់តែងដោយខុសប្លែកពីគ្នា គឺជាតុលាការជាតិមួយមាន“ភាពវិសាមញ្ញ”មានលក្ខណៈជាអន្តរជាតិ ។ អ្នកសង្កេតការណ៍អន្តរជាតិជាច្រើននឹងមើលព្រមទាំងសង្កេតអំពីដំណើរនៃកិច្ចការងារស៊ើបអង្កេតរាល់ថ្ងៃរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការកាត់ទោស ការពិភាក្សាច្បាប់ និងការដាក់ទោស ដោយមិនគ្របដណ្តប់ដោយបញ្ហានយោបាយដែលមានក្នុងសង្គមកម្ពុជា ។ វាគ្មានការសង្ស័យថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាការធ្វើពិសោធន៍ ប៉ុន្តែជាជម្រើសមួយដែលពុំអាចមានជម្រើសផ្សេងពីនេះក្នុងការផ្លាស់ប្តូរបន្ទាប់ពីកិច្ចចរចាជាច្រើនអស់រយៈពេលច្រើនឆ្នាំ ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចសម្រេចឲ្យបាននូវយុត្តិធម៌ដែលគួរឲ្យជឿទុកចិត្តបានក្នុងតុលាការកម្ពុជា នោះវានឹងបង្ហាញថាយុត្តិធម៌អន្តរជាតិ អាចសាយភាយនៅក្នុងចំណោមតុលាការជាតិ និងអន្តរជាតិ ជាមួយនឹងការទុកចិត្តខ្លាំងដែលយើងគួរតែអាចធ្វើការគិតឃើញតាំងពីទសវត្សរ៍មុន ។

ជាទីបញ្ចប់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាការសាកល្បងដ៏សំខាន់មួយរបស់អង្គការសហប្រជាជាតិ ដែលជាដៃគូយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការគ្រប់គ្រងបុគ្គលិកថវិកា និងការគ្រប់គ្រងអង្គជំនុំជម្រះ ។ សហគមន៍អន្តរជាតិ មិនចង់បានអ្វីទាំងអស់ពីរាជរដ្ឋាភិបាលកម្ពុជា ក្រៅពីចង់ឲ្យអង្គជំនុំជម្រះវិសាញ្ញក្នុងតុលាការកម្ពុជា និងរដ្ឋាភិបាលកម្ពុជាធ្វើតាមបទដ្ឋានខ្ពស់ដែលតម្រូវដោយមន្ត្រីអង្គការសហប្រជាជាតិ ។ តើអង្គការសហប្រជាជាតិរក្សាទំនាក់ទំនងដ៏ល្អជាមួយកម្ពុជាដោយរបៀបណា ដែលក្នុងទំនាក់ទំនងនេះត្រូវការភាពអត់ធ្មត់ សេចក្តីព្យាយាម ទំនាក់ទំនងការទូត និងការការពារនីតិរដ្ឋជាច្រើន ទំនាក់ទំនងនេះនឹងនិយាយច្រើនអំពីអង្គការអន្តរជាតិ ព្រមទាំង

*សមត្ថភាពដើម្បីគ្រប់គ្រងយន្តការប្លែក តែសំខាន់របស់យុត្តិធម៌នៅក្នុងស្រុកនិងអន្តរជាតិ ។ គេហទំព័រនៃអ្នកឃ្លាំមើលតុលាការកម្ពុជា (www.cambodiatribunal.org) ក៏ជាសកម្មភាពផ្សេងមួយ របស់អន្តរជាតិតែមួយ ។ គេហទំព័រនេះនឹង ចាក់ផ្សាយអំពីដំណើរការកាត់ទោសនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងសម្ភាសពីប្រតិកម្មរបស់ប្រជាជាតិខ្មែរចំពោះសាលាក្តី ។ ដោយនាំយកការកាត់ទោសឲ្យដឹងឮដល់ប្រជាជនបរទេសនិងដល់ប្រជាជនកម្ពុជាចេះប្រើអ៊ីនធឺណែតកំពុងតែកើនឡើង ។ អ្នកឃ្លាំមើលតុលាការកម្ពុជាមានបំណងដើម្បី បញ្ចប់នូវនិទណ្ឌភាពតាមរយៈការអប់រំនិងការយល់ដឹងពីអំពើដ៏ឃោរឃៅដែលកើតឡើងពីអតីតកាល ។ គោលបំណងនេះដំណើរការទៅបាន លុះត្រាតែជនជំនាន់ក្រោយទូទាំងពិភពលោកមិនបំភ្លេចអំពីអ្វីដែលបានកើតឡើងនៅកម្ពុជា ។*

**ដេវីត សេហ្វ័រ**
**សាស្ត្រាចារ្យច្បាប់និង**
**ជានាយកមជ្ឈមណ្ឌលសិទ្ធិមនុស្សអន្តរជាតិ**
**នៃសាកលវិទ្យាល័យច្បាប់ន័រវេសស្ទើន**